អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែងបង្កើតដើមឈើរ**

**ចិត្តចលភាព** ៖ បំណិនចលនាតូច៖ ការហ្រឹកហាត់ បង្កើនកម្លាំង និងសម្របសម្រួលរវាងចលនាសាច់ដុំដៃនិងសាច់ដុំភ្នែក៖

**វិទ្យាសាស្ត្រ** ៖ បំណិនអនាម័យ៖ ទម្លាប់រស់នៅមានអនាម័យក្នុងគ្រួសារនិងសង្គម៖

**សិក្សាសង្គម** ៖ បំណិនក្នុងសង្គម៖ ការយល់ដឹងអំពីបរិស្ថានធម្មជាតិនិងវិធីការពារ៖

គំនូរនិងសកម្មភាពកសាង៖ ការយល់ដឹងនិងការពេញចិត្តចំពោះសិល្បៈការរយៈការបង្កើតរូបភាព៖

**បុរេគណិត** ៖ បរិមាណនិងចំនួន៖ ស្គាល់នឹងយល់លេខតាងនិងការគណនាលេខសាមញ្ញ៖

ទំហំនិងពណ៌៖ ចំណាត់ថ្នាក់ក្រុមនិងលំដាប់លំដោយ៖

**ភាសាខ្មែរ** ៖ ការប្រើពាក្យតាមវេយ្យករណ៍៖ ការយល់ពីវាក្យស័ព្ទ ឃ្លា និងល្បះ៖

**<u>គោលបំណង</u>**

**ចិត្តចលភាព** ៖ វិជ្ជាសម្បទា៖

កំណត់ចំណុចគោលដៅនៃចលនាដៃដោយការទប់លំនឹងនិងសម្របសម្រួលទៅនឹងងភ្នែកក្នុងពេលធ្វើអ្វីមួយឬលេង ល្បែងបានរឹងមាំល្អ។

**វិទ្យាសាស្ត្រ** ៖ បំណិនសម្បទា៖ ចោលសំរាមនៅក្នុងធុងសំរាមឱ្យបានត្រឹមត្រូវ

**សិក្សាសង្គម** ៖ បំណិនសម្បទា៖ ជួយសម្អាតបរិស្ថាន ដូចជាការបោសសំរាម និងមិនបន្ទោរបង់ផ្តេសផ្តាសជាដើម។

វិជ្ជាសម្បទា៖ ប្រាប់បានពីរបៀបបត់ រោយ ដេរ ត្បាញ សូនរូប គូរ ផាត់ពណ៌ ហែក កាត់ បិទ បត់… ដើម្បីបង្កើតជារូបភាពផ្សេងៗបាន។

**បុរេគណិត** ៖ បំណិនសម្បទា៖ រាប់ចំនួនលេខ និងយល់ន័យពី១ដល់៣០ឬលើសពីនេះ។

បំណិនសម្បទា៖ រៀបវត្ថុតាមលំដាប់ក្រុម ប្រភេទ ទំហំ និងពណ៌។

**ភាសាខ្មែរ** ៖ វិជ្ជាសម្បទា៖ ប្រាប់ពីពាក្យ ឃ្លា ឬល្បះ ឱ្យបានត្រឹមត្រូវទៅតាមស្ថានភាព មនុស្សធំដែលមានចំនួនពី៥ទៅ៦ព្យាង្គឬលើសពីនេះ។

**កម្រិតសិក្សា** ៖ ទាប មធ្យម និងខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ប្រ៊ីត ដីខ្មៅ ដីខ្មៅពណ៌ បន្ទាត់ ក្រដាសពណ៌ ក្រដាសស កន្ត្រៃ កាវស្អិត

(ក្រដាសអាចប្រើក្រដាសដែលសល់ពីគេប្រើរួចក៏បានដែរ)

**ការរៀបចំ** ៖ បង្កើតជាដើមឈើឱ្យបាន២ប្រភេទ សម្រាប់បង្ហាញកុមារ មុននឹងឱ្យកុមារធ្វើដោយខ្លួនឯង។

**សេចក្តីណែនាំ៖**

1. សួរកុមារថាស្គាល់ដើមឈើអត់?
2. តើដើមឈើមានពណ៌អ្វី? ស្លឹកវាមានពណ៌អ្វី?
3. ប្រាប់កុមារថា ពួកគេនឹងទៅធ្វើជាដើមឈើរបស់ខ្លួនបានម្នាក់១ដើម ក្នុងពេលបន្តិចទៀតនេះ។
4. គ្រូបង្ហាញដើមឈើដែលបានធ្វើរួចទៅកាន់កុមារទាំងអស់គ្នាសិន
5. ចាប់ផ្តើមឱ្យកុមារបង្កើត ប្រាបពីរបៀបធ្វើទៅកាន់ទាំងអស់គ្នាជាមុនសិន៖

   សម្រាប់កុមារដែលមានអាយុ៥ឆ្នាំ

   ➔ ដំបូងត្រូវគូររូបដើមឈើក្នុងលើក្រដាសរាមពណ៌ស ជារាងដើមឈើ និងផាត់ពណ៌ផង តែមិនទាន់ដាក់ស្លឹកទេ

   ➔ បន្ទាប់មកទៀត គូរស្លឹកឈើនៅលើក្រដាសរាមពណ៌បៃតង

   ➔ រូបដើមឈើដែលបានគូររួចមុនហ្នឹង ត្រូវកាត់វាតាមរាងដែលបានគូរនោះ

   ➔ បន្ទាប់មក យកមកបិទនៅលើក្រដាសរាមសមួយផ្សេងទៀត ដែលប្រើកាវស្អិត

   ➔ បិទស្លឹកផង ឱ្យបានស្អាតជាកាស្រេច

   សម្រាប់កុមារដែលមានអាយុ៤ឆ្នាំ

   ➔ គូររូបប្រម្រាមដៃ និងកាត់ផាត់ពណ៌ឱ្យបានស្អាត

   ➔ កាត់ក្រដាសពណ៌បៃតងជារាងការ៉េ ល្មមនឹងចុងម្រាមដៃដែលបានគូរមុនហ្នឹង

   ➔ បន្ទាប់មក ក្រដាសបៃតងត្រូវបិទនៅចុងម្រាមដៃដោយប្រើកាវស្អិត ឱ្យបានស្អាតជាការស្រេច។
6. ល្បែងនេះ គ្រាន់តែលេងប៉ុណ្ណឹងជាការស្រេច